ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រុមប្រឹក្សាអាជ្ញាកណ្តាល
THE ARBITRATION COUNCIL

**លេខ និង ឈ្មោះសំណុំរឿង : ១៣/០៩ — ជូន តិចថាយល៍ (មិថុនា)**

**កាលបរិច្ឆេទនៃសេចក្តីបង្គាប់ : ថ្ងៃទី ២៣ ខែ កុម្ភៈ ឆ្នាំ ២០០៩**

# សេចក្តីបង្គាប់អាជ្ញាកណ្តាល

(ធ្វើឡើងស្របតាមមាត្រា៣១៣នៃច្បាប់ស្តីពីការងារ)

## សមាសភាពក្រុមអាជ្ញាកណ្តាល

អាជ្ញាកណ្តាលជ្រើសរើសឡើងដោយភាគីនិយោជកៈ **ឈើវ ភិរម្យ**

អាជ្ញាកណ្តាលជ្រើសរើសឡើងដោយភាគីកម្មករនិយោជិតៈ **អាន វីរៈ**

ប្រធានក្រុមអាជ្ញាកណ្តាលជ្រើសរើសឡើងដោយអាជ្ញាកណ្តាលទាំងពីរខាងលើៈ **គង់ ផល្លះ**

## ភាគីនៃវិវាទ

១- **ភាគីនិយោជក**

ឈ្មោះ : **ក្រុមហ៊ុន ជូន តិចថាយល៍ ខូ អិលធីឌី (មិថុនា)**

អាសយដ្ឋាន : មហាវិថីសហព័ន្ធរុស្ស៊ី សង្កាត់ទឹកថ្លា ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ

ទូរស័ព្ទ : ០១២ ៩៤១ ៨៥១ ទូរសារ : គ្មាន

តំណាងភាគីនិយោជក :

១- លោក អាល់ប៊ឺត តែវ នាយករដ្ឋបាល

២- លោក ម៉េង ត្រី ប្រធានរដ្ឋបាល

២- **ភាគីកម្មករនិយោជិត**

ក/- ឈ្មោះ : **សហជីពសេរីកម្មករ នៃរោងចក្រកាត់ដេរ ជូន តិចថាយល៍ (មិថុនា)**

អាសយដ្ឋាន : ផ្ទះលេខ ២៨ បេ ផ្លូវ ២២២ សង្កាត់ បឹងរាំង ខណ្ឌ ដូនពេញ រាជធានីភ្នំពេញ

លេខទូរស័ព្ទ : ០១២ ៨៨០ ០៣៩ លេខទូរសារ : គ្មាន

តំណាងកម្មករនិយោជិត:

១- កញ្ញា យ៉ាង សុភ័ណ្ឌ មន្ត្រីសហជីព FTUWKC

២- លោក យិន សារឿន ប្រធានសហជីពសេរីកម្មករប្រចាំរោងចក្រ មិថុនា

៣- លោក ជា វណ្ណនាថ អនុប្រធានសហជីពសេរីកម្មករប្រចាំរោងចក្រ មិថុនា

៤- លោកស្រី ផេង ជូ អគ្គលេខាធិការសហជីពសេរីកម្មករប្រចាំរោងចក្រ មិថុនា

៥- លោក ជួប នីត អគ្គលេខាធិការរងសហជីពសេរីកម្មករប្រចាំរោងចក្រ

៦- លោក ទូស សុភ័ណ្ឌ ហិរញ្ញិកសហជីពសេរីកម្មករប្រចាំរោងចក្រ

៧- លោក ប៉ុក សំរាត សកម្មជនសហជីព

ខ/- ឈ្មោះ : **សហព័ន្ធសហជីព-សហជីពយុវជនខ្មែរ នៃរោងចក្រកាត់ដេរ ជូន តិចថាយល៍ (មិថុនា)**

អាសយដ្ឋាន : មហាវិថីសហព័ន្ធរុស្ស៊ី សង្កាត់ទឹកថ្លា ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ

លេខទូរស័ព្ទ : ០៩២ ៦៤៩ ៤៧១ លេខទូរសារ : គ្មាន

តំណាងកម្មករនិយោជិត:

១- លោក ស៊ុំ ចន្ធា មន្ត្រីសំរបសំរួលសហព័ន្ធសហជីព KYFTU

២- លោក មុំ សារឿន ប្រធានសហជីពយុវជនខ្មែរប្រចាំរោងចក្រ មិថុនា

៣- លោក ផាន ឈឹម លេខាធិការសហជីព

៤- លោក សេង សំអូន ហិរញ្ញិកសហជីព

## បញ្ហាក្នុងវិវាទ

(នៅក្នុងរបាយការណ៍ផ្សះផ្សាមិនសះជា)

- សហជីពយុវជនខ្មែរ និងសហជីពសេរីកម្មករប្រចាំរោងចក្រ មិថុនា ស្នើឱ្យក្រុមហ៊ុនផ្តល់ប្រាក់ភាគទានសហជីពដែលក្រុមហ៊ុនបានកាត់រួចមក ក្នុងកំឡុងពេលសហជីពទាំងពីរមានវិវាទបញ្ហាសមាជិក។ ដោយឡែកក្រុមហ៊ុនមិនឯកភាពប្រគល់ប្រាក់ភាគទានសហជីពជូនសហជីពទាំងពីរបានទេ ដោយទុកឱ្យសហជីពទាំងពីរចរចារគ្នាសិន ហើយប្រាក់ទាំងនោះក្រុមហ៊ុនបានព្យួរបណ្តោះអាសន្ន ។

## អំណាចយុត្តាធិការរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល

ក្រុមប្រឹក្សាអាជ្ញាកណ្តាលទទួលអំណាចក្នុងការចេញសេចក្តីបង្គាប់នេះ ដោយយោងតាមជំពូកទី១២ ផ្នែកទីពីរ (ខ)(មាត្រា ៣០៩ ដល់ ៣១៧) នៃច្បាប់ស្តីពីការងារឆ្នាំ១៩៩៧ ប្រកាសស្តីពីក្រុមប្រឹក្សាអាជ្ញាកណ្តាល លេខ ០៩៩

សកបយ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ វិធាននៃនីតិវិធីក្រុមប្រឹក្សាអាជ្ញាកណ្តាល ដែលភ្ជាប់ជាឧបសម្ព័ន្ធនៃប្រកាសលេខ ០៩៩ សកបយ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ និងប្រកាសស្តីពីការតែងតាំងសមាជិកក្រុមប្រឹក្សាអាជ្ញាកណ្តាលលេខ ០៧៦/០៧ កកបវ./ប្រក ចុះថ្ងៃទី១០ ខែឧសភា ឆ្នាំ២០០៧ (អាណត្តិទី៥) ។

ការព្យាយាមផ្សះផ្សាវិវាទការងាររួម ដែលជាកម្មវត្ថុនៃសេចក្តីបង្គាប់នេះ ត្រូវបានធ្វើឡើងស្របតាមជំពូកទី១២ ផ្នែកទី២ (ក) នៃច្បាប់ស្តីពីការងារ ។ ប៉ុន្តែការផ្សះផ្សានោះ ភាគីទាំងពីរមិនបានឯកភាពសះជានឹងគ្នាឡើយ ហើយរបាយការណ៍ស្តីអំពីការមិនសះជា លេខ ០៦៣ ក.ប./អក/វក. ចុះថ្ងៃទី០២ ខែកុម្ភៈ ឆ្នាំ២០០៩ ត្រូវបានបញ្ជូនមកលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល នៅថ្ងៃទី០២ ខែកុម្ភៈ ឆ្នាំ២០០៩។

## សវនាការ និង សង្ខេបនីតិវិធីមុនពេលក្រុមប្រឹក្សាអាជ្ញាកណ្តាល

**ទីកន្លែងសវនាការ :** ក្រុមប្រឹក្សាអាជ្ញាកណ្តាល មជ្ឈមណ្ឌលភ្នំពេញ អគារ A វិថីសុធារស សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ ។

**កាលបរិច្ឆេទសវនាការ :** ថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ២០០៩ (វេលាម៉ោង ១៤:០០ នាទី ) ។

**បញ្ហានៃនីតិវិធី :**

នៅថ្ងៃទី៣០ ខែមករា ឆ្នាំ២០០៩ នាយកដ្ឋានវិវាទការងារបានទទួលបណ្តឹងរបស់ក្រុមហ៊ុន ចុះថ្ងៃទី៣០ ខែមករា ឆ្នាំ២០០៩ ពាក់ព័ន្ធនឹងប្រាក់ភាគទានសហជីពរបស់កម្មករនិយោជិត។ បន្ទាប់ពីបានទទួលពាក្យបណ្តឹងនេះមក នាយកដ្ឋានវិវាទការងារ បានចាត់តាំងមន្ត្រីជំនាញធ្វើការដោះស្រាយវិវាទការងារនេះ នៅថ្ងៃទី៣០ ខែមករា ឆ្នាំ២០០៩ ដដែល ប៉ុន្តែមិនបានទទួលលទ្ធផលសះជាទេ លើការទាមទារទាំងអស់ចំនួន ០១ ចំណុច។ ចំណុចមិនសះជាចំនួន ០១ ចំណុចនេះ ត្រូវបានបញ្ជូនមកលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល នៅថ្ងៃទី០២ ខែកុម្ភៈ ឆ្នាំ២០០៩។ បន្ទាប់ពីបានទទួលសំណុំរឿងរួចមក លេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាលបានធ្វើការកោះអញ្ជើញភាគីក្រុមហ៊ុន និងភាគីកម្មករនិយោជិតមកសវនាការ និងធ្វើការផ្សះផ្សាលើករណីមិនសះជាចំនួន ០១ ចំណុចនេះ នៅថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ២០០៩ (វេលាម៉ោង ១៤:០០ នាទី ) ។ ភាគីទាំងពីរមានវត្តមានតាមការកោះអញ្ជើញរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល ។

នៅថ្ងៃសវនាការ ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានព្យាយាមធ្វើការផ្សះផ្សាលើចំណុចមិនសះជាចំនួន ០១ ចំណុចនេះ ប៉ុន្តែមិនបានទទួលលទ្ធផលសះជាទេ។ ហេតុនេះហើយ នៅក្នុងរឿងនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលធ្វើការពិចារណាលើចំណុចវិវាទនេះ ដោយផ្អែកលើភស្តុតាង និង ហេតុផលដូចខាងក្រោមៈ

## ភស្តុតាង

**សាក្សី និង អ្នកជំនាញក្រៅពីភាគី : គ្មាន**

**ឯកសារ ភស្តុតាង ដែលក្រុមអាជ្ញាកណ្តាលយកមកពិចារណាមាន**

ក- ឯកសារបានទទួលពីភាគីនិយោជក ៖

១- សារណានៃវិវាទការងាររបស់ក្រុមហ៊ុន ជូន គិចថាយល៍ ចុះថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ២០០៩។

២- លិខិតជូនដំណឹងរបស់ឈ្មោះ យិន សារឿន ស្តីពីការផ្តិតមេដៃបញ្ជាក់ឱ្យក្រុមហ៊ុនដឹងឈ្មោះសមាជិកសហជីពសេរីកម្មករឱ្យបានជាក់លាក់ពិតប្រាកដ ចុះថ្ងៃទី១១ ខែសីហា ឆ្នាំ២០០៨ ។

៣- លិខិតស្នើសុំលាលែង និងឈប់កាត់ប្រាក់ឈ្នួលប្រចាំខែ ដើម្បីជួយវិភាគទានសហជីព របស់កម្មករឈ្មោះ សុទ្ធ ស្រី ចុះថ្ងៃទី១២ ខែធ្នូ ឆ្នាំ២០០៨ ។

៤- លិខិតស្នើសុំលាលែង និងឈប់កាត់ប្រាក់ឈ្នួលប្រចាំខែ ដើម្បីជួយវិភាគទានសហជីព របស់កម្មករឈ្មោះ មឿង ស៊ុន ចុះថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០០៨ ។

៥- លិខិតស្នើសុំលាលែង និងឈប់កាត់ប្រាក់ឈ្នួលប្រចាំខែ ដើម្បីជួយវិភាគទានសហជីព របស់កម្មករឈ្មោះ សាន វី ចុះថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០០៨ ។

៦- លិខិតស្នើសុំលាលែង និងឈប់កាត់ប្រាក់ឈ្នួលប្រចាំខែ ដើម្បីជួយវិភាគទានសហជីព របស់កម្មករឈ្មោះ ឡឿន សារ៉ែន ចុះថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០០៨ ។

៧- លិខិតស្នើសុំលាលែង និងឈប់កាត់ប្រាក់ឈ្នួលប្រចាំខែ ដើម្បីជួយវិភាគទានសហជីព របស់កម្មករឈ្មោះ ហួន ដានី ចុះថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ២០០៨ ។

៨- លិខិតស្នើសុំលាលែង និងឈប់កាត់ប្រាក់ឈ្នួលប្រចាំខែ ដើម្បីជួយវិភាគទានសហជីព របស់កម្មករឈ្មោះ ឈុំ ឌីម ចុះថ្ងៃទី១៧ ខែតុលា ឆ្នាំ២០០៨ ។

៩- លិខិតស្នើសុំលាលែង និងឈប់កាត់ប្រាក់ឈ្នួលប្រចាំខែ ដើម្បីជួយវិភាគទានសហជីព របស់កម្មករឈ្មោះ មោត សាម៉ាន ចុះថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ២០០៨ ។

១០- លិខិតស្នើសុំលាលែង និងឈប់កាត់ប្រាក់ឈ្នួលប្រចាំខែ ដើម្បីជួយវិភាគទានសហជីព របស់កម្មករឈ្មោះ ភាង សា ។

១១- លិខិតស្នើសុំលាលែង និងឈប់កាត់ប្រាក់ឈ្នួលប្រចាំខែ ដើម្បីជួយវិភាគទានសហជីព របស់កម្មករឈ្មោះ ម៉ៅ ចាន់ធឿន ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០០៨ ។

១២- លិខិតស្នើសុំលាលែង និងឈប់កាត់ប្រាក់ឈ្នួលប្រចាំខែ ដើម្បីជួយវិភាគទានសហជីព របស់កម្មករឈ្មោះ ឈិត សុផុន ចុះថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០០៨ ។

១៣- លិខិតស្នើសុំលាលែង និងឈប់កាត់ប្រាក់ឈ្នួលប្រចាំខែ ដើម្បីជួយវិភាគទានសហជីព របស់កម្មករឈ្មោះ ប៉ាង សំណោង ចុះថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០០៨ ។

១៤- លិខិតស្នើសុំលាលែង និងឈប់កាត់ប្រាក់ឈ្នួលប្រចាំខែ ដើម្បីជួយវិភាគទានសហជីព របស់កម្មករឈ្មោះ ឃឹម សៀប ចុះថ្ងៃទី២១ ខែតុលា ឆ្នាំ២០០៨ ។

១៥- លិខិតស្នើសុំលាលែង និងឈប់កាត់ប្រាក់ឈ្នួលប្រចាំខែ ដើម្បីជួយវិភាគទានសហជីព របស់កម្មករ ឈ្មោះ ម៉ែ ឃីម ចុះថ្ងៃទី២១ ខែតុលា ឆ្នាំ២០០៨ ។

១៦- លិខិតស្នើសុំលាលែង និងឈប់កាត់ប្រាក់ឈ្នួលប្រចាំខែ ដើម្បីជួយវិភាគទានសហជីព របស់កម្មករ ឈ្មោះ ប្រាក់ ខោម៉ា ចុះថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០០៨ ។

១៧- លិខិតស្នើសុំលាលែង និងឈប់កាត់ប្រាក់ឈ្នួលប្រចាំខែ ដើម្បីជួយវិភាគទានសហជីព របស់កម្មករ ឈ្មោះ វ៉ន សភា ចុះថ្ងៃទី២៤ ខែតុលា ឆ្នាំ២០០៨ ។

១៨- លិខិតស្នើសុំលាលែង និងឈប់កាត់ប្រាក់ឈ្នួលប្រចាំខែ ដើម្បីជួយវិភាគទានសហជីព របស់កម្មករ ឈ្មោះ នង ចន្ទី ចុះថ្ងៃទី១១ ខែតុលា ឆ្នាំ២០០៨ ។

១៩- លិខិតស្នើសុំលាលែង និងឈប់កាត់ប្រាក់ឈ្នួលប្រចាំខែ ដើម្បីជួយវិភាគទានសហជីព របស់កម្មករ ឈ្មោះ សោម ធីតា ចុះថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០០៨ ។

២០- លិខិតស្នើសុំលាលែង និងឈប់កាត់ប្រាក់ឈ្នួលប្រចាំខែ ដើម្បីជួយវិភាគទានសហជីព របស់កម្មករ ឈ្មោះ ថេង ចាន់ហេង ចុះថ្ងៃទី០៤ ខែវិច្ឆិកា ឆ្នាំ២០០៨ ។

២១- លិខិតស្នើសុំលាលែង និងឈប់កាត់ប្រាក់ឈ្នួលប្រចាំខែ ដើម្បីជួយវិភាគទានសហជីព របស់កម្មករ ឈ្មោះ ឆេង មួយជឹម ចុះថ្ងៃទី២២ ខែធ្នូ ឆ្នាំ២០០៨ ។

២២- លក្ខន្តិកៈក្រុមហ៊ុន ជូន តិចថាយល័ ចុះបញ្ជីពាណិជ្ជកម្ម លេខ ៥៩៤/០៤ ពណ.នតក.បព ចុះថ្ងៃទី០៤ ខែមិថុនា ឆ្នាំ២០០៤ ។

២៣- វិញ្ញាបនប័ត្របញ្ជាក់ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មក្រុមហ៊ុន ជូន តិចថាយល័ លេខ ៣៨២៣ ពណ. ចបព ចុះថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០០៨ ។

២៤- បទបញ្ជាផ្ទៃក្នុងក្រុមហ៊ុន ជូន តិចថាយល័ ចុះបញ្ជិកាលេខ ០២៧ សកអ.អក ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ១៩៩៨ ។

២៥- លិខិតស្នើសុំលាលែង និងឈប់កាត់ប្រាក់ឈ្នួលប្រចាំខែ ដើម្បីជួយវិភាគទានសហជីព របស់កម្មករ ឈ្មោះ សុខ ចន្ធូ ចុះថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០០៨ ។

២៦- លិខិតស្នើសុំលាលែង និងឈប់កាត់ប្រាក់ឈ្នួលប្រចាំខែ ដើម្បីជួយវិភាគទានសហជីព របស់កម្មករ ឈ្មោះ ហៃ ឆដា ចុះថ្ងៃទី២៤ ខែវិច្ឆិកា ឆ្នាំ២០០៨ ។

២៧- លិខិតស្នើសុំលាលែង និងឈប់កាត់ប្រាក់ឈ្នួលប្រចាំខែ ដើម្បីជួយវិភាគទានសហជីព របស់កម្មករ ឈ្មោះ ខេម សុត ចុះថ្ងៃទី១៨ ខែធ្នូ ។

២៨- លិខិតស្នើសុំលាលែង និងឈប់កាត់ប្រាក់ឈ្នួលប្រចាំខែ ដើម្បីជួយវិភាគទានសហជីព របស់កម្មករ ឈ្មោះ ប៉ាក់ សុខលី ចុះថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០០៨ ។ 6

២៩- លិខិតស្នើសុំលាលែង និងឈប់កាត់ប្រាក់ឈ្នួលប្រចាំខែ ដើម្បីជួយវិភាគទានសហជីព របស់កម្មករ ឈ្មោះ និន ណេន ចុះថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០០៨ ។

៣០- លិខិតស្នើសុំលាលែង និងឈប់កាត់ប្រាក់ឈ្នួលប្រចាំខែ ដើម្បីជួយវិភាគទានសហជីព របស់កម្មករ ឈ្មោះ ប្រាក់ អឿន ចុះថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០០៨ ។

៣១- លិខិតស្នើសុំលាលែង និងឈប់កាត់ប្រាក់ឈ្នួលប្រចាំខែ ដើម្បីជួយវិភាគទានសហជីព របស់កម្មករ ឈ្មោះ អឹម លក្ខិណា ចុះថ្ងៃទី២២ ខែមករា ឆ្នាំ២០០៨ ។

៣២- លិខិតស្នើសុំលាលែង និងឈប់កាត់ប្រាក់ឈ្នួលប្រចាំខែ ដើម្បីជួយវិភាគទានសហជីព របស់កម្មករ ឈ្មោះ រុំ សារិត ចុះថ្ងៃទី២៣ ខែមករា ឆ្នាំ២០០៨ ។

៣៣- លិខិតស្នើសុំលាលែង និងឈប់កាត់ប្រាក់ឈ្នួលប្រចាំខែ ដើម្បីជួយវិភាគទានសហជីព របស់កម្មករ ឈ្មោះ អ៊ុល វណ្ណនី ចុះថ្ងៃទី១៦ ខែមករា ឆ្នាំ២០០៨ ។

៣៤- លិខិតស្នើសុំលាលែង និងឈប់កាត់ប្រាក់ឈ្នួលប្រចាំខែ ដើម្បីជួយវិភាគទានសហជីព របស់កម្មករ ឈ្មោះ នៃ ចិន្តា ចុះថ្ងៃទី២៣ ខែមករា ឆ្នាំ២០០៨ ។

៣៥- លិខិតស្នើសុំលាលែង និងឈប់កាត់ប្រាក់ឈ្នួលប្រចាំខែ ដើម្បីជួយវិភាគទានសហជីព របស់កម្មករ ឈ្មោះ នង ចន្នី ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០០៨ ។

៣៦- លិខិតស្នើសុំលាលែង និងឈប់កាត់ប្រាក់ឈ្នួលប្រចាំខែ ដើម្បីជួយវិភាគទានសហជីព របស់កម្មករ ឈ្មោះ អ៊ុក លីណា ចុះថ្ងៃទី១៩ ខែមករា ឆ្នាំ២០០៨ ។

៣៧- លិខិតស្នើសុំលាលែង និងឈប់កាត់ប្រាក់ឈ្នួលប្រចាំខែ ដើម្បីជួយវិភាគទានសហជីព របស់កម្មករ ឈ្មោះ ស៊ឿន ឡេន ចុះថ្ងៃទី០៦ ខែមីនា ឆ្នាំ២០០៨ ។

៣៨- លិខិតស្នើសុំលាលែង និងឈប់កាត់ប្រាក់ឈ្នួលប្រចាំខែ ដើម្បីជួយវិភាគទានសហជីព របស់កម្មករ ឈ្មោះ ឆន រ៉ែន ចុះថ្ងៃទី០២ ខែកុម្ភៈ ឆ្នាំ២០០៨ ។

៣៩- លិខិតស្នើសុំលាលែង និងឈប់កាត់ប្រាក់ឈ្នួលប្រចាំខែ ដើម្បីជួយវិភាគទានសហជីព របស់កម្មករ ឈ្មោះ រុំ សារិត ចុះថ្ងៃទី៣១ ខែមករា ឆ្នាំ២០០៨ ។

៤០- លិខិតស្នើសុំលាលែង និងឈប់កាត់ប្រាក់ឈ្នួលប្រចាំខែ ដើម្បីជួយវិភាគទានសហជីព របស់កម្មករ ឈ្មោះ ចាន់ សុភាន់ ចុះថ្ងៃទី០១ ខែកុម្ភៈ ឆ្នាំ២០០៨ ។

៤១- លិខិតស្នើសុំលាលែង និងឈប់កាត់ប្រាក់ឈ្នួលប្រចាំខែ ដើម្បីជួយវិភាគទានសហជីព របស់កម្មករ ឈ្មោះ អុល សម្ភស្ស ចុះថ្ងៃទី០៦ ខែមីនា ឆ្នាំ២០០៨ ។

៤២- លិខិតស្នើសុំលាលែង និងឈប់កាត់ប្រាក់ឈ្នួលប្រចាំខែ ដើម្បីជួយវិភាគទានសហជីព របស់កម្មករ ឈ្មោះ ង៉េត ទុំ ចុះថ្ងៃទី១០ ខែមីនា ឆ្នាំ២០០៨ ។

ខ- ឯកសារបានទទួលពីភាគីកម្មករនិយោជិត :

**សហជីពសេរីកម្មករ :**

១- លិខិតស្នើសុំលាលែង និងឈប់កាត់ប្រាក់ឈ្នួលប្រចាំខែ ដើម្បីជួយវិភាគទានសហជីព របស់កម្មករ ឈ្មោះ អ៊ឹម ស្រីនាង ចុះថ្ងៃទី០២ ខែកុម្ភៈ ឆ្នាំ២០០៩ ។

២- លក្ខន្តិកៈសហជីពសេរីកម្មករនៃរោងចក្រកាត់ដេរ មិថុនា ចុះបញ្ជិកា ១៣៣ សកបយ.អក ចុះថ្ងៃទី ០៦ ខែវិច្ឆិកា ឆ្នាំ២០០០ ។

៣- វិញ្ញាបនប័ត្រចុះបញ្ជិកាសហជីពសេរីកម្មក នៃរោងចក្រកាត់ដេរ មិថុនា ចុះថ្ងៃទី០៦ ខែវិច្ឆិកា ឆ្នាំ ២០០០ ។

៤- លិខិតរបស់ប្រធាននាយកដ្ឋានវិវាទការងារ ជំរាបមក លោកប្រធានសហជីពសេរីកម្មករនៃរោងចក្រ កាត់ដេរ មិថុនា លេខ ៨៧៥ កកបវ/អក/វក ចុះថ្ងៃទី១៤ ខែសីហា ឆ្នាំ២០០៨ ។

**សហជីពយុវជនខ្មែរ :**

- លិខិតរបស់ប្រធាននាយកដ្ឋានវិវាទការងារ ជំរាបមក លោកប្រធានសហជីពយុវជនខ្មែរ នៃរោងចក្រ កាត់ដេរ មិថុនា លេខ ៦២០ កកបវ/អក/វក ចុះថ្ងៃទី០៦ ខែមិថុនា ឆ្នាំ២០០៨ ។

**គ- ឯកសារបានទទួលពីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

១- របាយការណ៍ស្តីពីការដោះស្រាយវិវាទការងាររួមនៅក្រុមហ៊ុន មិថុនា លេខ ០៦៣ ក.ប/អក/វ.ក ចុះថ្ងៃទី០២ ខែកុម្ភៈ ឆ្នាំ២០០៩។

២- កំណត់ហេតុដោះស្រាយវិវាទការងាររួមរបស់ក្រុមហ៊ុន មិថុនា ចុះថ្ងៃទី៣០ ខែមករា ឆ្នាំ២០០៩។

**ឃ- ឯកសារបានទទួលពីលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល**

១- លិខិតអញ្ជើញភាគីនិយោជកចូលរួមសវនាការ លេខ ០៦០ កប/អក/វក/លកអ. ចុះថ្ងៃទី ០៣ ខែ កុម្ភៈ ឆ្នាំ ២០០៩។

២- លិខិតអញ្ជើញភាគីសហជីពសេរីកម្មករ ចូលរួមសវនាការ លេខ ០៦១ កប/អក/វក/លកអ.ចុះថ្ងៃទី ០៣ ខែ កុម្ភៈ ឆ្នាំ ២០០៩។

៣- លិខិតអញ្ជើញភាគីសហជីពយុវជនខ្មែរ ចូលរួមសវនាការ លេខ ០៦២ កប/អក/វក/លកអ.ចុះថ្ងៃទី ០៣ ខែ កុម្ភៈ ឆ្នាំ ២០០៩។

**សន្ធរហេតុ**

- ក្រោយពីបានពិនិត្យឯកសារផ្សេងៗ ដែលត្រូវបានដាក់ជូនមកក្រុមប្រឹក្សាអាជ្ញាកណ្តាល
- ក្រោយពីបានពិនិត្យរបាយការណ៍នៃការផ្សះផ្សាវិវាទការងាររួម
- ក្រោយពីបានស្តាប់អំណះអំណាងរបស់តំណាងភាគីកម្មករនិយោជិត និង ភាគីនិយោជក

4

ក្រុមប្រឹក្សាអាជ្ញាកណ្ដាលរកឃើញថា :

- រោងចក្រជូន តិចថាយល៍ មានកម្មករសរុបប្រហែល ៤៨០០ នាក់។
- ក្រុមហ៊ុន គឺជាដើមបណ្ដឹងនៅក្នុងរឿងបញ្ហាប្រាក់ភាគទានសហជីពនេះ ។
- ក្នុងរោងចក្រនេះមានសហជីពពីរ គឺសហជីពសេរីកម្មករនៃព្រះរាជាណាចក្រកម្ពុជាដែលបានបង្កើតនៅក្នុងឆ្នាំ២០០០ ហើយមានសមាជិក ២៥០៨ នាក់ និងសហជីពយុវជនខ្មែរ បង្កើតនៅឆ្នាំ២០០៣ ដែលមានសមាជិកចំនួន ១២២៨ នាក់។
- នៅក្នុងសវនាការភាគីក្រុមហ៊ុនបញ្ជាក់ថា ក្រុមហ៊ុនទាមទារប្រើសិទ្ធិកាត់ ឬ មិនកាត់ប្រាក់ឈ្នួល កម្មករនិយោជិត ដើម្បីជួយភាគទានសហជីព នៅពេលមានលិខិតស្នើសុំឈប់កាត់ប្រាក់ឈ្នួលប្រចាំខែ ដើម្បីជួយភាគទានសហជីពពីកម្មករនិយោជិត ដោយមិនឱ្យមានបញ្ហាជាមួយនឹងសហជីពសេរីកម្មករនៃព្រះរាជាណាចក្រកម្ពុជា និងសហជីពយុវជនខ្មែរ។
- សហជីពសេរីកម្មករនៃព្រះរាជាណាចក្រកម្ពុជា ជាភាគីកម្មករនិយោជិត ដែលជាចុងចម្លើយ និងមានវិវាទជាមួយក្រុមហ៊ុន ចំណែកឯសហជីពយុវជនខ្មែរមិនមែនជាភាគីវិវាទក្នុងរឿងនេះទេ។ ក្នុងសវនាការសហជីពយុវជនខ្មែរបានបញ្ជាក់ថា កម្មករចំនួន ១៩ នាក់ ដែលបានលាឈប់ពីសហជីពសេរីកម្មករនៃព្រះរាជាណាចក្រកម្ពុជានោះ គ្រាន់តែបានពឹងពួកគេឱ្យយក**លិខិតស្នើសុំលាលែង និងឈប់កាត់ប្រាក់ឈ្នួលប្រចាំខែ ដើម្បីជួយភាគទានសហជីព**សេរីកម្មករនៃព្រះរាជាណាចក្រកម្ពុជា ទៅដាក់នៅរដ្ឋបាលក្រុមហ៊ុនប៉ុណ្ណោះ ហើយមិនបានពឹងពាក់អ្វីទៀតទេ ហើយការដែលមកចូលរួមសវនាការនេះគឺ ដើម្បីតាមដានសំណុំរឿងប៉ុណ្ណោះ។ សហជីពយុវជនខ្មែរបានបញ្ជាក់ទៀតថា កម្មករនិយោជិតទាំង ១៩ នាក់នេះ មិនមែនជាសមាជិកសហជីពយុវជនខ្មែរទេ។ សហជីពមិនទាន់ប្រាកដថា ពួកគេនឹងចូលរួមជាមួយសហជីពយុវជនខ្មែរ ឬ យ៉ាងណានោះដែរ។
- នៅក្នុងសវនាការក្រុមហ៊ុនបញ្ជាក់ថា ក្រុមហ៊ុនបានអនុវត្តការកាត់ប្រាក់ឈ្នួលកម្មករនិយោជិតតាមការស្នើសុំរបស់កម្មករនិយោជិត ដើម្បីបង់ភាគទានសហជីពទៅឱ្យសហជីពទាំងពីរ ចាប់តាំងពីពេលដែលសហជីពសេរីបានបង្កើតនៅឆ្នាំ២០០០ និងសហជីពយុវជនខ្មែរបានបង្កើតឆ្នាំ២០០៣។
- ប៉ុន្តែសម្រាប់ខែធ្នូ ឆ្នាំ២០០៨ និងខែមករា ឆ្នាំ២០០៩ នេះ ក្រុមហ៊ុនបានកាត់ប្រាក់ឈ្នួលសម្រាប់បង់ភាគទានសហជីពរបស់កម្មករនិយោជិត ដែលជាសមាជិកសហជីពសេរីកម្មករនៃព្រះរាជាណាចក្រកម្ពុជា ចំនួន ១៩ នាក់ ហើយបានរក្សាទុកនៅក្នុងក្រុមហ៊ុន ដោយមិនបានប្រគល់ឱ្យសហជីពសេរីកម្មករនៃព្រះរាជាណាចក្រកម្ពុជាទេ ទោះបីជាភាគីក្រុមហ៊ុនបានទទួល**លិខិតស្នើសុំលាលែង និងឈប់កាត់ប្រាក់ឈ្នួលប្រចាំខែ**

**ដើម្បីជួយភាគទានសហជីព**របស់កម្មករនិយោជិតចំនួន ១៩ នាក់ ដែលបានសុំលាឈប់ពីសហជីពសេរីកម្មករនៃព្រះរាជាណាចក្រកម្ពុជាក៏ដោយ។

- នៅក្នុងសវនាការ ភាគីក្រុមហ៊ុនបានបញ្ជាក់ថា ក្នុងចំណោមលិខិតស្នើសុំទាំង ១៩ នាក់នេះ ក្រុមហ៊ុនបានទទួល**លិខិតស្នើសុំលាលែង និងឈប់កាត់ប្រាក់ឈ្នួលប្រចាំខែ ដើម្បីជួយភាគទានសហជីព**សេរីកម្មករនៃព្រះរាជាណាចក្រកម្ពុជា ពីកម្មករនិយោជិតផ្ទាល់ និងមួយចំនួនពីសហជីពយុវជនខ្មែរផង។
- សហជីពសេរីកម្មករនៃព្រះរាជាណាចក្រកម្ពុជាបានបញ្ជាក់ថា **លិខិតស្នើសុំលាលែង និងឈប់កាត់ប្រាក់ឈ្នួលប្រចាំខែ ដើម្បីជួយភាគទានសហជីព** ទាំង ១៩ នាក់ នោះមិនត្រឹមត្រូវទេ ព្រោះមិនមានត្រា ឬហត្ថលេខារបស់ប្រធានសហជីពសេរីកម្មករប្រចាំរោងចក្រ ។ សហជីពបានបញ្ជាក់ថា តាមទម្លាប់អនុវត្តកន្លងមក **លិខិតស្នើសុំលាលែង និងឈប់កាត់ប្រាក់ឈ្នួលប្រចាំខែ ដើម្បីជួយភាគទានសហជីព** ត្រូវមានហត្ថលេខារបស់ប្រធានសហជីពសេរីកម្មករប្រចាំរោងចក្រ។ ប៉ុន្តែ ចាប់ពីថ្ងៃទី១១ ខែសីហា ឆ្នាំ២០០៨មក សហជីពសេរីកម្មករនៃព្រះរាជាណាចក្រកម្ពុជាបានអនុវត្តគោលការណ៍ថ្មី ដោយតម្រូវឱ្យមានត្រា និងហត្ថលេខារបស់ប្រធានសហជីពសេរីកម្មករប្រចាំរោងចក្រនៅលើលិខិតសុំលាលែង ពីសហជីពសេរីកម្មករនៃព្រះរាជាណាចក្រកម្ពុជា។ សហជីពបានបញ្ជាក់ថា ផ្អែកតាមប្រការ ២៧ នៃលក្ខន្តិកៈរបស់សហជីព កម្មករនិយោជិតដែលលាឈប់ពីសហជីពត្រូវតែដាក់ពាក្យលាលែង ជូនទៅប្រធានសហជីព។ តាមទម្លាប់កម្មករនិយោជិតដែលចង់លាឈប់នោះ មកប្រាប់ប្រធានសហជីពដោយផ្ទាល់ ហើយប្រធានសហជីពនឹងចុះហត្ថលេខាលើ**លិខិតស្នើសុំលាលែង និងឈប់កាត់ប្រាក់ឈ្នួលប្រចាំខែ ដើម្បីជួយភាគទានសហជីព** ប៉ុន្តែមិនមែនដាក់លិខិតស្នើសុំលាលែង និងឈប់កាត់ប្រាក់ឈ្នួលប្រចាំខែ ដើម្បីជួយភាគទានហជីព ពីសហជីពផ្សេង ឬ ពីក្រុមហ៊ុនឡើយ។ ហេតុនេះ ក្រុមហ៊ុនមិនអាចឈប់កាត់ប្រាក់ឈ្នួល ដើម្បីជួយភាគទានសហជីពរបស់កម្មករនិយោជិតដែលជាសមាជិកសហជីពសេរីកម្មករ ក្នុងករណីបានទទួលលិខិតស្នើសុំលាលែង និងឈប់កាត់ប្រាក់ឈ្នួលប្រចាំខែ ដើម្បីជួយភាគទានសហជីពដែលគ្មានត្រា និងហត្ថលេខារបស់ប្រធានសហជីពសេរីកម្មករប្រចាំរោងចក្រនោះទេ ។
- ក្រុមហ៊ុនបានបញ្ជាក់ថា ជួនកាលក្រុមហ៊ុនបានទទួលឯកសារអត់ត្រា និងហត្ថលេខាលើ**លិខិតស្នើសុំលាលែង និងឈប់កាត់ប្រាក់ឈ្នួលប្រចាំខែ ដើម្បីជួយភាគទានសហជីព**ដែរ។ ក្រុមប្រឹក្សាអាជ្ញាកណ្តាលបង្គាប់ឱ្យក្រុមហ៊ុនផ្តល់ឯកសារទាំងនេះមកក្រុមប្រឹក្សាអាជ្ញាកណ្តាលនៅថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ២០០៩។ ភាគីក្រុមហ៊ុនបញ្ជាក់ថា នៅពេលដែលក្រុមហ៊ុនបានទទួល**លិខិតស្នើសុំលាលែង និងឈប់កាត់ប្រាក់ឈ្នួលប្រចាំខែ ដើម្បីជួយភាគទានសហជីព** ក្រុមហ៊ុនតែងតែឈប់កាត់ប្រាក់ឈ្នួលរបស់កម្មករនិយោជិត ដើម្បីជួយភាគទានឱ្យសហជីព ។ ប៉ុន្តែក្នុងករណីនេះ ក្រុមហ៊ុនបានកាត់ប្រាក់ឈ្នួលកម្មករនិយោជិត ក្រោយពីបានទទួល**លិខិតស្នើសុំលាលែង និងឈប់កាត់ប្រាក់ឈ្នួលប្រចាំខែ ដើម្បីជួយភាគទានសហជីព** ដោយ

4

ព្រួយបារម្ភអំពីបញ្ហាដែលអាចកើតឡើងជាមួយសហជីពសេរីកម្មករនៃព្រះរាជាណាចក្រកម្ពុជា តែក្រុមហ៊ុនបានរក្សាប្រាក់ភាគទានរបស់កម្មករនិយោជិតទាំង១៩ នាក់នេះទុកនៅក្រុមហ៊ុន ដោយមិនបានប្រគល់ឱ្យសហជីពសេរីទេ ព្រោះព្រួយបារម្ភអំពីបញ្ហាដែលអាចកើតឡើងជាមួយសហជីពយុវជនខ្មែរ ។

- ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានទទួល**លិខិតស្នើសុំលាលែង និងឈប់កាត់ប្រាក់ឈ្នួលប្រចាំខែ ដើម្បីជួយភាគទានសហជីព**ពីភាគីក្រុមហ៊ុនពាក់ព័ន្ធនឹងកម្មករចំនួន១៩ នាក់ដែលក្រុមហ៊ុនបានកាត់ប្រាក់ឈ្នួលរបស់ពួកគេនៅខែធ្នូ ឆ្នាំ២០០៨ និងខែមករា ឆ្នាំ២០០៩ ដែលក្រុមហ៊ុនបានរក្សាប្រាក់ឈ្នួលនោះទុកសិន។ ប៉ុន្តែឯកសារនោះមានកម្មករនិយោជិតម្នាក់ឈ្មោះ ម៉ៅ ចាន់ធឿន អត្តលេខ ១២៣៧ ដែលកម្មកររូបនេះបានដាក់**លិខិតស្នើសុំលាលែង និងឈប់កាត់ប្រាក់ឈ្នួលប្រចាំខែ ដើម្បីជួយភាគទានសហជីព** តាំងពីថ្ងៃទី ១៦ ខែតុលា ឆ្នាំ២០០៧។ សូមមើលតារាងខាងក្រោម :

| លេខរៀង | ឈ្មោះ | កាលបរិច្ឆេទនៃលិខិតស្នើសុំលាឈប់ និងឈប់កាត់ប្រាក់ឈ្នួលដើម្បីជួយភាគទានសហជីព |
|---|---|---|
| ១ | ម៉ៅ ចាន់ធឿន | ១៦-១០-២០០៧ |
| ២ | មឿង ស៊ុន | ០១-១២-២០០៨ |
| ៣ | សាន វី | ១៣-១២-២០០៨ |
| ៤ | ធឿន សារ៉ែន | ២១-១១-២០០៨ |
| ៥ | ហួន ដានី | ០១-១១-២០០៨ |
| ៦ | ឈុំ ឌឹម | ១៧-១០-២០០៨ |
| ៧ | មោត សាម៉ាន | ០១-១១-២០០៨ |
| ៨ | ភាង សា | ១៩-១២-២០០៨ |
| ៩ | ឈិត សុផុន | ១៩-១២-២០០៨ |
| ១០ | សុទ្ធ ស្រី | ២២ -១២-២០០៨ |
| ១១ | ប៉ាត សំណាង | ១៩-១២-២០០៨ |
| ១២ | ឃឹម សៀប | ២១-១០-២០០៨ |
| ១៣ | ម៉ៃ ឃឹម | ២១-១០-២០០៨ |
| ១៤ | ប្រាក់ ខេម៉ា | ១៥-១១-២០០៨ |
| ១៥ | រិន សុភា | ២៤-១០-២០០៨ |
| ១៦ | នង ចន្ធី | ១១-១០-២០០៨ |

| | | |
|---|---|---|
| ១៧ | សោម ធីតា | ១៥-១១-២០០៨ |
| ១៨ | ថេង ចាន់ហេង | ០៤-១១-២០០៨ |
| ១៩ | ឆេង មួយនីម | ២២-១២-២០០៨ |

## ហេតុផលនៃសេចក្តីសំរេច

ក្នុងករណីនេះ ក្រុមហ៊ុនទាមទារប្រើសិទ្ធិកាត់ ឬ មិនកាត់ប្រាក់ឈ្នួលកម្មករនិយោជិត ដើម្បីជួយភាគទានសហជីព នៅពេលមានលិខិតស្នើសុំពីកម្មករនិយោជិត ដោយមិនឱ្យមានបញ្ហាជាមួយនឹងសហជីពសេរីកម្មករនៃព្រះរាជាណាចក្រកម្ពុជា និងសហជីពយុវជនខ្មែរ ។ ក្រុមហ៊ុនស្នើសុំឱ្យក្រុមប្រឹក្សាអាជ្ញាកណ្តាល សម្រេចលើករណីនេះ នៅក្នុងសវនាការ ។ ក្រុមប្រឹក្សាអាជ្ញាកណ្តាលធ្វើការពិចារណា លើករណីនេះដូចខាងក្រោមៈ

មាត្រា ១២៩ កថាខណ្ឌ២ នៃច្បាប់ស្តីពីការងារចែងថា *"......កម្មករនិយោជិតអាចអនុញ្ញាតឱ្យកាត់ប្រាក់ឈ្នួលរបស់ខ្លួន ដើម្បីបង់ភាគទានសហជីពដែលខ្លួនជាសមាជិក ។ ការអនុញ្ញាតនេះត្រូវធ្វើជាលាយលក្ខណ៍អក្សរ និងអាចបដិសេធវិញបានគ្រប់ពេលវេលា"* ។

ផ្អែកលើខ្លឹមសារនៃមាត្រា ១២៩ កថាខ័ណ្ឌទី២នេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា មាត្រានេះមិនអនុវត្តចំពោះការស្នើសុំកាត់ប្រាក់ឈ្នួលកម្មករនិយោជិតពីសហជីពដែលជានីតិបុគ្គលទេ គឺ អនុវត្តចំពោះកម្មករនិយោជិត និងក្រុមហ៊ុនទាក់ទងនឹងការកាត់ប្រាក់ឈ្នួល ដើម្បីបង់ភាគទានសហជីព ។ មាត្រានេះតម្រូវឱ្យនិយោជកកាត់ប្រាក់ឈ្នួលកម្មករនិយោជិត ដើម្បីបង់ភាគទានសហជីព ក្នុងករណីមានការស្នើសុំជាលាយលក្ខណ៍អក្សរពីកម្មករនិយោជិត ដែលជាសមាជិកសហជីពដោយផ្ទាល់ ។ ប៉ុន្តែមាត្រានេះ ក៏បានបើកសិទ្ធិឱ្យកម្មករនិយោជិតដែលជាសមាជិកសហជីពធ្វើការបដិសេធគ្រប់ពេល ក្នុងករណីដែលកម្មករនិយោជិតមានបំណងសុំឈប់ឱ្យក្រុមហ៊ុនកាត់ប្រាក់ឈ្នួលរបស់ពួកគេ ដើម្បីបង់ប្រាក់ភាគទានសហជីព ។

ក្រុមប្រឹក្សាអាជ្ញាកណ្តាលនៅក្នុងសេចក្តីបង្គាប់លេខ ៦០/០៥-អេវើហ្គ្រីន យល់ឃើញថា *" គោលបំណងនៃការតម្រូវឱ្យមានការអនុញ្ញាតជាលាយលក្ខណអក្សរក្នុងការកាត់ប្រាក់ភាគទានសហជីពនេះ គឺដើម្បីការពារកម្មករនិយោជិតម្នាក់ៗ ពីការកាត់ប្រាក់ឈ្នួលរបស់កម្មករនិយោជិតផ្ទុយពីឆន្ទៈរបស់ពួកគាត់ និងដើម្បីការពារក្រុមហ៊ុនពីកំហុសឆ្គងក្នុងការកាត់ប្រាក់ឈ្នួលរបស់កម្មករនិយោជិត ។ ទាំងនេះ គឺជាផលប្រយោជន៍នៃការព្រួយបារម្ភ ដើម្បីធានាថា ឯកសារសុំកាត់ប្រាក់ឈ្នួលទាំងអស់ត្រឹមត្រូវ និងបង្ហាញពីឆន្ទៈ និងគោលបំណងពិតប្រាកដរបស់កម្មករនិយោជិតម្នាក់ៗ ។"*

ផ្អែកតាម សេចក្តីបង្គាប់អាជ្ញាកណ្តាលខាងលើនេះ ឃើញថា ដើម្បីធានាកុំឱ្យមានការកាត់ប្រាក់ឈ្នួលផ្ទុយពីឆន្ទៈកម្មករនិយោជិត ឯកសារសុំកាត់ប្រាក់ឈ្នួលទាំងអស់ត្រូវមានលក្ខណៈត្រឹមត្រូវ និងច្បាស់លាស់ ។ ហេតុនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា ការដែលកម្មករនិយោជិតមិនមានឆន្ទៈឱ្យនិយោជកកាត់ប្រាក់ឈ្នួល

សម្រាប់បង់វិភាគទានសហជីពបន្តទៅទៀតនោះទេ កម្មករនិយោជិតត្រូវមានការបង្ហាញច្បាស់លាស់ដែលមានលក្ខណៈត្រឹមត្រូវដែលការបង្ហាញនោះអាចតាមរយៈលិខិត ឬ វិធីណាមួយដែលចាត់ទុកថាបានការ ។

ម៉្យាងទៀត តាមការបកស្រាយនៃមាត្រា ១២៩ នៃច្បាប់ស្តីពីការងារខាងលើ សិទ្ធិនៃការស្នើសុំឱ្យកាត់ប្រាក់ឈ្នួល ឬ មិនកាត់ ដើម្បីបង់វិភាគទានសហជីព គឺជាសិទ្ធិផ្តាច់មុខរបស់កម្មករនិយោជិត តាមរយៈលិខិតជាលាយលក្ខណ៍អក្សរ ។ ដូច្នេះ ប្រសិនបើនិយោជកទទួលបាននូវលិខិតស្នើសុំពីកម្មករនិយោជិត ដែលបង្ហាញពីចេតនាច្បាស់លាស់ថា កម្មករនិយោជិតណាដែលលែងឱ្យកាត់ប្រាក់ឈ្នួលបង់វិភាគទានទៀតហើយនោះ និយោជកមិនត្រូវកាត់ប្រាក់ឈ្នួលកម្មករនិយោជិត ឬ រក្សានូវចំណែកដែលកាត់ហើយនោះទុកឡើយ ។

ក្នុងសំណុំរឿងនេះ ក្រុមហ៊ុនបានកាត់ប្រាក់ឈ្នួលកម្មករនិយោជិត ទោះបីជានិយោជកទទួលបាននូវលិខិតជាលាយលក្ខណ៍អក្សរពីកម្មករនិយោជិតថា សុំឈប់ឱ្យកាត់ប្រាក់ឈ្នួល ដើម្បីបង់សហជីពតទៅទៀតក៏ដោយ ហើយនិយោជកថែមទាំងបានរក្សាប្រាក់ភាគទានរបស់កម្មករនិយោជិតទាំង ១៩ នាក់ នេះទុកនៅក្រុមហ៊ុន ដោយមិនប្រគល់ឱ្យទៅកម្មករវិញនោះឡើយ ។ ផ្អែកលើការបកស្រាយខាងលើ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា ករណីនេះក្រុមហ៊ុនបានប្រើសិទ្ធិរបស់ខ្លួនមិនត្រឹមត្រូវគឺ ក្រុមហ៊ុនបានកាត់ និងបានរក្សាប្រាក់ភាគទានរបស់កម្មករនិយោជិតទាំង ១៩ នាក់នេះ ទុកនៅក្រុមហ៊ុន ដោយមិនប្រគល់ឱ្យទៅកម្មករនិយោជិតវិញទេ បើទោះបីជាមាន **លិខិតស្នើសុំលាលែង និងឈប់កាត់ប្រាក់ឈ្នួលប្រចាំខែ ដើម្បីជួយភាគទានសហជីព** របស់កម្មករនិយោជិតទាំង ១៩ នាក់ ក៏ដោយ ។

ដូច្នេះ ក្រុមហ៊ុនត្រូវប្រគល់ប្រាក់នោះឱ្យកម្មករនិយោជិតវិញ គឺមិនត្រូវរក្សាប្រាក់ភាគទានរបស់កម្មករនិយោជិតទាំង ១៩ នាក់នេះ ទុកនៅក្រុមហ៊ុនឡើយ ។

យោងតាមការបង្ហាញពីអង្គហេតុ អង្គច្បាប់ និង ហេតុផល ដូចបានបញ្ជាក់ខាងលើក្រុមប្រឹក្សាអាជ្ញាកណ្តាលសំរេចៈ

## សម្រេច និងបង្គាប់

- បង្គាប់ឱ្យក្រុមហ៊ុនបញ្ឈប់ការកាត់ប្រាក់ឈ្នួលប្រចាំខែរបស់កម្មករនិយោជិត ក្នុងការបង់ជូនភាគទានសហជីពនៅពេលបានទទួលលិខិតស្នើសុំឱ្យឈប់កាត់របស់កម្មករនិយោជិត និងសងប្រាក់ឈ្នួលដែលបានកាត់ទុក ជូនទៅកម្មករនិយោជិតវិញ តាមកាលបរិច្ឆេទនៃលិខិតស្នើសុំលាលែង ។

**ប្រភេទនៃសេចក្តីបង្គាប់ : សេចក្តីបង្គាប់ជាប់កាតព្វកិច្ច**

*សេចក្តីបង្គាប់នេះនឹងក្លាយជាស្ថាពរភ្លាម ហើយអនុវត្តចំពោះភាគីតែម្តង បន្ទាប់ពីសេចក្តីបង្គាប់នេះចេញទៅ ដោយភាគីទាំងពីរបានយល់ព្រមជ្រើសរើសយកសេចក្តីបង្គាប់នេះ នៅថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ២០០៩ ។*

## ហត្ថលេខារបស់សមាជិកក្រុមអាជ្ញាកណ្ដាល

អាជ្ញាកណ្ដាលជ្រើសរើសដោយភាគីនិយោជក :

ឈ្មោះ : **ឈឹម គិរម្យ**

ហត្ថលេខា: ------------------------------

អាជ្ញាកណ្ដាលជ្រើសរើសដោយភាគីកម្មករនិយោជិត :

ឈ្មោះ : **អាន វីរៈ**

ហត្ថលេខា: ------------------------------

ប្រធានក្រុមអាជ្ញាកណ្ដាល :

ឈ្មោះ : **គង់ ផល្លះ**

ហត្ថលេខា: ------------------------------